**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អ្នកនាំពាក្យ គ.ជ.ប**
**លេខ៖** ០០៧ **គ.ជ.ប**

ថ្ងៃចន្ទ ១០កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធអំពីដំណើរការនៃការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុង និងស្រុក ទើបបង្កើតថ្មី

នាព្រឹកថ្ងៃចន្ទ ទី១៦ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅសាលសន្និសីទសារព័ត៌មានរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានបើកកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ក្រោមអធិបតីភាព **ឯកឧត្តម នុត សុខុម** អនុប្រធាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីប្រតិទិននៃការបោះឆ្នោតលើកទី១ (ការបោះឆ្នោតឡើងវិញ) ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូននៃខេត្តកណ្តាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យនៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យនៃខេត្តក្រចេះ ឆ្នាំ២០២៣។

**ឯកឧត្តម នុត សុខុម** បានមានប្រសាសន៍ថា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន ៤ ដោយបង្កើតក្រុងអរិយក្សត្រ និងក្រុងសំពៅពូននៃខេត្តកណ្តាល បង្កើតស្រុកអូរគ្រៀងសែនជ័យនៃខេត្តក្រចេះ និងបំបែកស្រុកឧដុង្គនៃខេត្តកំពង់ស្ពឺជាពីរ គឺក្រុងឧដុង្គម៉ែជ័យ និងស្រុកសាមគ្គីមុនីជ័យ។ អនុលោមតាមមាត្រា ៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាសម្រាប់ក្រុង ស្រុក ខណ្ឌ បង្កើតថ្មីក្នុងរយៈពេលយ៉ាងយូរ ២៤០ថ្ងៃ បន្ទាប់ពីការបង្កើត។ តាមរយៈសេចក្តីសម្រេចលេខ ០២ ស.ស.រ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានកំណត់យក**ថ្ងៃអាទិត្យ ទី៩ ខែមេសា ឆ្នាំ២០២៣** ជាកាលបរិច្ឆេទនៃការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សាទាំងនេះ។

សម្រាប់ការបោះឆ្នោតឡើងវិញនេះ **ឯកឧត្តម នុត សុខុម** បានមានប្រសាសន៍ថា អ្នកសង្កេតការណ៍ជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចបញ្ជូនតំណាងរបស់ខ្លួនមកចូលរួមសង្កេតមើលការបោះឆ្នោតឡើងវិញ ដោយត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះមក គ.ជ.ប ចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។ ចំណែកអ្នកសង្កេតការណ៍អន្តរជាតិត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិនៅ គ.ជ.ប ចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ នេះ រហូតដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

**ឯកឧត្តម នុត សុខុម** បានបន្តថា សម្រាប់អ្នកសារព័ត៌មានជាតិ ដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការនៃការបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់ទៅ គ.ជ.ប ចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។ ចំណែកអ្នកសារព័ត៌មានអន្តរជាតិ អាចដាក់ពាក្យចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ នេះ រហូតដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។

**ឯកឧត្តម នុត សុខុម** បានមានប្រសាសន៍បន្ថែមថា សម្រាប់គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ ស្តីពីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ មានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូននៃខេត្តកណ្តាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យនៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យនៃខេត្តក្រចេះ។ ការចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ត្រូវធ្វើនៅគណៈកម្មការរៀបចំការបោះឆ្នោតនៃខេត្តសាមីពាក់ព័ន្ធចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣។

**ឯកឧត្តម នុត សុខុម** បានបញ្ជាក់ថា ចំពោះការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសង្កេតមើលការរៀបចំការបោះឆ្នោត ត្រូវធ្វើនៅគណៈកម្មការរៀបចំការបោះឆ្នោតនៃខេត្តសាមីពាក់ព័ន្ធ តាមទម្រង់បែបបទដែលកំណត់ដោយ គ.ជ.ប។ ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសង្កេតមើលការរៀបចំការបោះឆ្នោត ត្រូវចែកជា ២ ដំណាក់កាល គឺដំណាក់កាលនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលការចុះឈ្មោះបោះឆ្នោត និងដំណាក់កាលនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំបានមានចម្ងល់ថា៖

១. តើអាចយកបេក្ខជនពីស្រុកផ្សេងៗ ដើម្បីឈរឈ្មោះបោះឆ្នោតបានដែរ ឬទេ?

២. តើអ្នកណាខ្លះមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នេះបាន?

៣. តើដីដែលរដ្ឋាភិបាលប្រគល់ឱ្យមក គ.ជ.ប នោះ គ.ជ.ប នឹងយកមកធ្វើអ្វី?

ឆ្លើយតបនឹងសំណួរ និងសំណូមពររបស់ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំ តំណាង គ.ជ.ប បានឆ្លើយថា បេក្ខជនឈរឈ្មោះបោះឆ្នោតមកពីស្រុកផ្សេងៗឱ្យតែមានសិទ្ធិបោះឆ្នោត និងមានការបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ ក៏អាចដាក់ពាក្យឈរឈ្មោះជាបេក្ខជនបានដែរ។

សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នេះ អ្នកដែលមានសិទ្ធិបោះឆ្នោតបាន គឺមានតែសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែងដែលស្ថិតនៅក្នុងក្រុង ស្រុក ខណ្ឌនោះប៉ុណ្ណោះ។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

គ.ជ.ប បានទទួលដំណឹងតាមការប្រកាសរបស់រាជរដ្ឋាភិបាល ហើយ គ.ជ.ប សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានប្រគល់ដីដែលជារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មកឱ្យ គ.ជ.ប ដើម្បីរៀបចំកសាងអគារទីស្តីការ គ.ជ.ប។

នេះជាកិច្ចប្រជុំលើកទី១ ជាមួយភាគីពាក់ព័ន្ធ សម្រាប់ការបោះឆ្នោតលើកទី១ (ការបោះឆ្នោតឡើងវិញ) ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុងសំពៅពូននៃខេត្តកណ្តាល ក្រុងឧដុង្គម៉ែជ័យ ស្រុកសាមគ្គីមុនីជ័យនៃខេត្តកំពង់ស្ពឺ និងស្រុកអូរគ្រៀងសែនជ័យនៃខេត្តក្រចេះ ឆ្នាំ២០២៣ ដែលសមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមានមកពីក្រសួងការពារជាតិ ក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋសភា ព្រឹទ្ធសភា កងរាជអាវុធហត្ថ ក្រសួងមហាផ្ទៃ វេទិកាសម្ព័ន្ធសង្គមស៊ីវិលនៃទីស្តីការគណៈរដ្ឋមន្ត្រី អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកសារព័ត៌មានផងដែរ ចំនួនប្រមាណជាជាង ៣០នាក់៕



អគារ គ.ជ.ប ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh